គណៈកម្មាធិការព្រំដែនកម្ពុជា
សមាគម មិនជាប់ពាក់ព័ន្ធ នឹង គណៈបក្ស នយោបាយ
Comité des Frontières du Cambodge ( C F C )
Cambodia's Border Committee ( C B C )
ASSOCIATION NON APPARENTEE AU PARTI POLITIQUE ASSOCIATION UNAFFILIATED TO A POLITICAL PARTY

CFC-CBC 17072012 K

# ព្រំដែនខ្មែរ ក្នុងអង្គប់យួន

ក្នុងរយៈកាលបីឆ្នាំកន្លងមក មេដឹកនាំនៃក្រុងហាណូយ បានឆ្លៀតគ្រប់ឱកាសដែលបានជួបគ្នា ជំរុញលោកហ៊ុន សែន ឲ្យបញ្ចប់យ៉ាងឆាប់ នូវការបោះបង្គោលព្រំដែន រវាងកម្ពុជានិងយៀកណាម។ នាខែមិថុនា ២០១៥ ដោយបានថ្កោលទោសយ៉ាងខ្លាំង ដល់អំពើឃោរឃៅ នៅព្រំដែន នៅខែត្រត្បូងឃ្មុំ និងស្វាយរៀង - ដែលពួកយួន បានបង្កសោះ! - ក្រុងហាណូយបានបង្ខំទាមទារ ជាថ្មីទៀត ឲ្យ "ប្រទេសទាំងពីរ បញ្ចប់ ការកំណត់បន្ទាត់ព្រំដែន និង បោះបង្គោល ក្នុងឆ្នាំ២០១៥នេះ តែម្ដង"។

នៅមុខការបង្ខឹតបង្ខំរបស់យួន ក្នុងរយៈកាលបីឆ្នាំនោះ លោកហ៊ុន សែន ហាក់ដូចជាធ្វើប្រងើយកន្តើយ ដោយប្រហែលជាបានឃើញជាក់ស្ដែង នូវការរំលោភឥតឈប់ឈរ បំពានលើ"សន្ធិសញ្ញាបំពេញបន្ថែម" ឆ្នាំ២០០៥ តែម្ដង ក្នុងកិច្ចការកំណត់បន្ទាត់ព្រំដែន និងបោះបង្គោលលើទីដីផ្ទាល់នោះ។ ដល់ខែមិថុនានិងខែវិច្ឆិកា ២០១៥នេះ លោក ហោ ណាំហុង និង វ៉ា គិមហុង ដែលជារដ្ឋមន្ត្រី របស់ ហ៊ុន សែន បានសំរេចចិត្ត បើកបង្ហាញ រឿងរំលោភរបស់យួនហ្នឹង ជាសាធារណៈតែម្ដង ដោយបានទាំងបញ្ជាក់ នូវបរាជ័យជាបន្តបន្ទាប់ ជាច្រើនឆ្នាំមកហើយ នៃការចរចាគ្នា (ជាសម្ងាត់) នៅក្នុងគណៈកម្មាធិការចម្រុះ យួន-ខ្មែរ។ មកដល់កាចរចាបីថ្ងៃទៀត នៃគណៈកម្មាធិការចម្រុះហ្នឹង ពីថ្ងៃទី៧ កក្កដា ២០១៥នេះ ក៏មិនបានលទ្ធផលអ្វីសោះ ក្នុងបញ្ហាកំណត់បន្ទាត់ព្រំដែន និងបោះបង្គោលលើទីដី ក្រៅពីការសន្យាស្រពិចស្រពិល របស់យួន ថា គេនឹង"ពិនិត្យម្ដងទៀត" អំពីរឿងស្រះនៅរតនៈគីរី និងរឿងសាងថ្នល់តាមព្រំដែន នៅស្វាយរៀង។

យើងមើលឃើញថា គោលដៅរបស់ក្រុងហាណូយ ខណៈដែលមានសភាពការណ៍តឹងតែង កាន់តែខ្លាំងឡើងៗ រវាងយួននិងចិន ក្នុងបញ្ហាកោះ នៅក្នុងសមុទ្រចិនខាងត្បូង គឺគេបញ្ចប់ឲ្យស្រេចបាច់ភ្លាម ជាប្រយោជន៍ធំដល់គេ នូវខ្សែព្រំដែនដីគោក ជាមួយខ្មែរ ហើយនឹងបន្តជាបន្ទាប់ នូវការកំណត់ព្រំដែន-សមុទ្រ ដើម្បីបញ្ចូលជាស្ថាពរ នូវកោះត្រល់ កោះក្រចកសេះ និងដែនសមុទ្រខ្មែរមួយភាគធំ ដែលហាណូយបានកាត់យក ដោយកម្លាំងអាវុធ នៅក្នុង"កិច្ចព្រមព្រៀង"ខុសច្បាប់មួយ ជាមួយ ហ៊ុន សែន នាឆ្នាំ ១៩៨២។ វិធីឈ្លានពានយួន ឥតមានផ្លាស់ប្ដូរទេ ជាច្រើនសតវត្សមកហើយ មកទល់និងទសវត្ស១៩៧០ គឺ ដោយសារគេមានកម្លាំងយោធាខ្លាំងក្លា យួនផ្ដើមចូលកាន់កាប់ទឹកដីខ្មែរ នៅជាប់ព្រំដែន ដែលគេថាវាគ្មានការកំណត់ច្បាស់លាស់ (សព្វថ្ងៃ គេហៅថា"តំបន់ ស") ដើម្បីតាំង ទី

លំនៅ ធ្វើស្រែចំការ ព្រមទាំងតាំងបន្ទាយយោធាផង ក្នុងការរង់ចាំវាយប្រហារខ្មែរ ឬធ្វើសង្គ្រាមធំ ដើម្បីបង្ខំភាគីខ្មែរ ឲ្យសុខចិត្ត កំណត់បន្ទាត់ព្រំដែនមួយថ្មី នៅមុខទឹកដី ដែលគេបានចូល មកកាន់កាប់ហើយនោះ។ រួចហើយ យួនក៏បន្តវិធីឈ្លានពានហ្នឹង ម្តងទៀត ដើម្បីចូលកាត់យកទឹកដីខ្មែរថ្មីៗទៀត ដោយគ្មានគិតឈឺក្បាល និង"កិច្ចព្រមព្រៀង"អ្វីៗ ពីពេលមុននោះទេ។នេះហើយជាអង្គប់របស់យួន។

ឥឡូវនេះទៀត បញ្ហាកណ្តាលធំ គឺរឿងផែនទី ដែលខ្មែរនិងយួនត្រូវប្រើ ដើម្បីធ្វើការកំណត់បន្ទាត់ព្រំដែន និង ការបោះបង្គោល ថ្មីៗទៀត។ នាថ្ងៃទី២ កក្កដា ២០១៥ លោក វ៉ា គិមហុង បានបញ្ជាក់ថា ផែនទី"'តែមួយ" ដែលគណៈកម្មាធិការចម្រុះយួន-ខ្មែរ បានប្រើមកទល់ពេលនេះ គឺជាផែនទី ដែល "យៀកណាមបានធ្វើឲ្យ" ដោយចម្លងពីផែនទីបារាំង ខ្នាត១/១០០០០០ ដែលអតិត"ព្រះមហាក្សត្រ នរោត្តម សីហនុ បានយកទៅតម្កល់ នៅអង្គការសហប្រជាជាតិ នាឆ្នាំ១៩៦៤"។ តែ អ្នកតំណាងរាស្ត្រនៃបក្សប្រឆាំង"សង្គ្រោះជាតិកម្ពុជា" បានអះអាង ដូចគ្នានិងសេចក្តីប្រកាស នៃព្រះមហាក្សត្រ នរោត្តម សីហនុ កាលពីខែធ្នូ២០០៤ ថា ផែនទីយួនឲ្យមកនោះ ជាផែនទីបារាំង"ក្លែងក្លាយ"។ ម្យ៉ាងទៀត គណៈកម្មាធិការចម្រុះយួន-ខ្មែរ បានប្រើផែនទីមួយទៀត ខ្នាត១/៥០០០០០ ដែលកងទ័ពអាមេរិកបានធ្វើ នាឆ្នាំ១៩៧០ (ជាមួយយួនខាងត្បូង) ដែលកម្ពុជាមិនដែលទទួលស្គាល់ឡើយ។ ហេតុនេះ អ្នកតំណាងរាស្ត្រនៃបក្សប្រឆាំង ក៏បានទាមទារ ដោយសមហេតុផល ឲ្យរដ្ឋាភិបាល ហ៊ុន សែន លុប"សន្ធិសញ្ញាបំពេញបន្ថែម" ឆ្នាំ២០០៥នោះ ចោលវិញទៅ ត្បិតវាខុសនិងបទបញ្ញត្តិ នៃរដ្ឋមនុញ្ញកម្ពុជា និងខុសនិងច្បាប់អន្តរជាតិ។

លុះថ្ងៃទី៦ កក្កដា ២០១៥ស្រាប់តែលោកហ៊ុន សែនសំរេចចិត្ត សរសេរសំបុត្រ ទៅអគ្គលេខាធិការ នៃអង្គការសហប្រជាជាតិ សុំ"ខ្ចី"ផែនទីកម្ពុជា ដែលអតិត"ព្រះមហាក្សត្រ នរោត្តម សីហនុ បានយកទៅតម្កល់ នៅអង្គការនោះ នាឆ្នាំ១៩៦៤ ដើម្បី"ឲ្យមានការធានារ៉ាប់រង ពីសំណាក់មហាអំណាចនានា ក្នុងការគោរពបូរណភាពទឹកដីកម្ពុជា តាមផ្លូវច្បាប់អន្តរជាតិ ក្នុងរង្វង់ខ្សែព្រំដែនបច្ចុប្បន្ន នាពេលនោះ ដោយបានប្រកាសដាច់ខាត ថាខ្សែព្រំដែននេះ មិនអាចសើរើ និងកែប្រែ បានឡើយ" ហើយដែល ហ៊ុន សែន "គោរពខ្ជាប់ខ្ជួន ឥតងាករេ"ឡើយ ។ហ៊ុន សែនបានបញ្ជាក់ផងទៀតថាផែនទីនរោត្តម សីហនុ ឆ្នាំ១៩៦៤នេះ នឹង"ប្រើប្រាស់ដើម្បីផ្ទៀងផ្ទាត់ បញ្ជាក់អំពីភាពត្រឹមត្រូវពិតប្រាកដ ជាមួយផែនទី ដែលរាជរដ្ឋាភិបាលកម្ពុជា បាននឹងកំពុងប្រើប្រាស់ សម្រាប់កំណត់ព្រំដែនគោក និងព្រំដែនទឹក រវាងព្រះរាជាចក្រកម្ពុជា ជាមួយនឹងប្រទេសជិតខាង"។ នាថ្ងៃទី១៥ កក្កដា ២០១៥ លោកហ៊ុន សែន បាន សរសេរសំបុត្រក្នុងន័យដូចគ្នានេះ ទៅឲ្យប្រទេសមហាអំណាចបីទៀត គឺ បារាំង អង់គ្លេស និងសហរដ្ឋអាមេរិក ដោយថែមទាំងសុំជំនួយ នៃអ្នកបច្ចេកទេស ឲ្យមកជួយ ក្នុងការផ្ទៀងផ្ទាត់ផែនទីនានា ផង។

អ្នកខ្លះបានយល់ថា នេះជាសញ្ញា នៃការផ្លាស់ប្តូរឥរិយាបថ នៃហ៊ុន សែន ចំពោះយៀកណាម។ ប៉ុន្តែ តើគេអាចទុកចិត្ត លើការសន្យា(ជាថ្មីទៀត)នេះ របស់មនុស្សម្នាក់ ដែលក្នុងរយៈកាល២០ឆ្នាំមកនេះ តែងតែភរភូត និងបំភាន់មតិ ប្រជាជនខ្មែរ ឥតឈប់ឈរ ក្នុងបញ្ហាព្រំដែនខ្មែរ-យួននេះ ឬទេ?។

សំនួរទី១របស់យើង គឺ ដោយហេតុថា អស់រយៈកាលបីឆ្នាំមកហើយ ដែលការចរចាជាមួយយួន មិនបានផលល្អអ្វីសោះ តើលោកហ៊ុន សែន មានមធ្យោបាយនិងសេចក្តីក្លាហានគ្រប់គ្រាន់ ដើម្បីសើរើ ឬ ប្រកាសបោះបង់ "សន្ធិសញ្ញា បំពេញបន្ថែម" ឆ្នាំ២០០៥ នោះឬទេ ? ។

ការធ្វើសមតាមហេតុផល និងត្រឹមត្រូវតាមច្បាប់ គឺគាត់យករឿងនេះ ទៅឲ្យហត្ថលេខីនានា នៃកិច្ចព្រមព្រៀងសន្តិភាព នៅទីក្រុងប៉ារីស ឆ្នាំ១៩៩១ ស្តីពីកម្ពុជា ពិនិត្យនិងវិនិច្ឆ័យ ត្បិតកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីសនេះ បានធានាយ៉ាងច្បាស់ លើ"ការថែរក្សា និងការការពារ នៃអធិបតេយ្យ ឯករាជ្យ បូរណភាពទឹកដី និងភាពមិនអាចរំលោភបាននៃទឹកដី នៃប្រទេសកម្ពុជា"។ នេះជាការដោះស្រាយបញ្ហា តាមការទូត ដ៏ប្រសើរបំផុត ដែលយៀកណាម មិនអាចប្រកែក មិនចូលខ្លួន និងមិនទទួលការខុសត្រូវបានទេ ដោយហេតុថាយៀកណាម ក៏ជាហត្ថលេខីមួយដែរ នៃកិច្ចព្រមព្រៀង នៅទីក្រុងប៉ារីសហ្នឹង។

បើលោកហ៊ុន សែន ធ្វើក្រៅផ្លូវនេះ គឺគាត់រុញរឿងទឹកដីខ្មែរ ឲ្យនៅក្នុងអង្គប់មរណៈ របស់ពួកវាតទីនិយមយួន ដ៏មហាឧក្រិដ្ឋ ដដែល។

*ទីក្រុងប៉ារីស ថ្ងៃទី១៧ កក្កដា ២០១៥*

ជ. គណៈកម្មាធិការ ព្រំដែនកម្ពុជា នៅប្រទេសបារាំង និង ក្នុងពិភពលោក

**ឌី ការ៉េត**